# សាលាកប័ត្រព័ត៌មាន ៖ ការបណ្ដេញចេញដោយបង្ខំនៅកម្ពុជា អំឡុងពេល កូវីដ១៩

**ទិដ្ឋភាពរួម ៖** ថ្វីបើស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជាមានសភាពកាន់តែធ្ងន់ធ្ងរតាំងពីដើមឆ្នាំ២០២១ មកក៏ដោយការបណ្ដេញចេញដោយបង្ខំនៅតែបន្តអនុវត្ត ដោយពុំបានអនុលោមតាមគោលការណ៍សិទ្ធិមនុស្សពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការបណ្ដេញចេញនោះទេ ជាពិសេសឆ្លើយតបនឹងសិទ្ធិមានលំនៅឋានសមរម្យ ដែលអ្នកជំនាញរបស់អង្គការសហប្រជាជាតិ ("អ.ស.ប") បានទទួលស្គាល់ថាជាគន្លឹះក្នុងការឆ្លើយតបទៅនឹងជំងឺរាតត្បាតដ៏កាចសាហាវនេះ។[1] សាលាកប័ត្រព័ត៌មាននេះត្រូវបានចងក្រងឡើងដោយយោងទៅតាមសាលាកប័ត្ររបស់មជ្ឈមណ្ឌលសិទ្ធិមនុស្ស ("ម.ស.ម.ក") ដែលបានចេញផ្សាយកាលពីឆ្នាំ២០២០[2] និងផ្ដោតលើការបណ្ដេញចេញដោយបង្ខំនៅកម្ពុជាក្នុងអំឡុងពេលមានការរីករាលដាលនៃជំងឺកូវីដ១៩។ សាលាកប័ត្រព័ត៌មាននេះក៏រំលឹកអំពីកាតព្វកិច្ចសិទ្ធិមនុស្សរបស់តួអង្គ គឺរដ្ឋ និងធុរកិច្ច ដើម្បីការពារពលរដ្ឋពីការរំលោភសិទ្ធិមនុស្សនិងការផ្ដល់ជាអនុសាសន៍ជាក់ស្ដែងដល់រាជរដ្ឋាភិបាលកម្ពុជា("រាជរដ្ឋាភិបាល")ឱ្យបញ្ឈប់ការបណ្ដេញចេញដោយបង្ខំ និងការពារលំនៅឋានរបស់ពលរដ្ឋក្នុងបរិបទនៃវិបត្តិសុខភាពពិភពលោកដែលកំពុងកើតមានឡើង ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការគោរពសិទ្ធិដីធ្លី និងសេរីភាពជាមូលដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ១. សេចក្ដីផ្ដើម

ការបណ្ដេញចេញដោយបង្ខំគឺជាផ្នែកមួយនៃការរំលោភសិទ្ធិដីធ្លីដែលរីករាលដាលបំផុត ដែលជាញឹកញាប់តែងតែបង្ខំបុគ្គលជាច្រើនឱ្យក្លាយជាអ្នកគ្មានផ្ទះសម្បែង ឬរាំងជនរងគ្រោះពីការរកចំណូលចិញ្ចឹមជីវិត។ ការបណ្ដេញចេញដោយបង្ខំបណ្ដាលឱ្យមានវិសមភាពកាន់តែខ្លាំងឡើង និងប៉ះពាល់ដល់សហគមន៍ក្រីក្រ ដោយបានបោះបង់សហគមន៍ទាំងនោះ ព្រមទាំងរុញច្រានជនក្រីក្រ និងជនដែលងាយរងគ្រោះបំផុតធ្លាក់ទៅក្នុងភាពក្រីក្របន្ថែមទៀត។

**ការបណ្ដេញចេញដោយបង្ខំគឺជាទម្រង់នៃការរំលោភសិទ្ធិមនុស្សមួយ** ជាពិសេសរំលោភលើសិទ្ធិទទួលបានលំនៅឋានសមរម្យ ក៏ដូចជាសិទ្ធិដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិជាច្រើន រួមទាំងសិទ្ធិសន្តិសុខបុគ្គលនិងសិទ្ធិជនជាតិដើម

[1] បាឡាគ្រិសនា រ៉ាចាកូប៉ាល អ្នករាយការណ៍ពេសេសរបស់ អ.ស.ប ស្ដីពីសិទ្ធិលំនៅឋានសមរម្យ របាយការណ៍សង្ខេបរបស់មហាសន្និបាតលើកទី ៧៥របស់ អ.ស.ប (អេ/៧៥/១៤៨ ខែកក្កដា ឆ្នាំ២០២០)

[2] ម.ស.ម.ក "សាលាកប័ត្រព័ត៌មាន ៖ ការបណ្ដេញចេញដោយបង្ខំនៅកម្ពុជា" (ម.ស.ម.ក ខែតុលា ឆ្នាំ២០២០)។

ភាគតិចចំពោះទឹកដីជាលក្ខណៈប្រពៃណីរបស់ពួកគេ។[3]

> **តើអ្វីទៅជាការបណ្តេញចេញដោយបង្ខំ?**
> ការបណ្តេញចេញដោយបង្ខំគឺ "ការជម្លៀសបុគ្គល គ្រួសារ និង/ឬសហគមន៍ជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ចេញពីផ្ទះ និង/ឬដីធ្លីរបស់ពួកគេដែលកំពុងកាន់កាប់ ដែលផ្ទុយពីឆន្ទៈរបស់ពួកគេ ដោយគ្មានការផ្តល់ និងការទទួលបាននូវទម្រង់សមស្របនៃការការពារស្របច្បាប់ ឬទម្រង់ការពារផ្សេងទៀត"
>
> *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌(មតិទូទៅលេខ៧, ង/*

តាមគោលការណ៍សិទ្ធិមនុស្សអន្តរជាតិការបណ្តេញចេញដោយបង្ខំ ត្រូវបានអនុញ្ញាតតែនៅក្នុងកាលៈទេសៈជាក់លាក់និងមានកំណត់អប្បបរមា ហើយ**ត្រូវតែមានយុត្តិធម៌ពេញលេញដែលអនុញ្ញាតដោយច្បាប់ និងត្រូវគោរពតាមវិធានសិទ្ធិមនុស្សអន្តរជាតិ និងការដោះស្រាយតាមផ្លូវច្បាប់ពេញលេញត្រូវតែមានចំពោះអ្នករងផលប៉ះពាល់**។[4] នេះជា**ការទទួលខុសត្រូវរបស់រដ្ឋក្នុងការការពារប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ** ដោយធានាថាការបណ្តេញចេញ ត្រូវបានអនុញ្ញាតដោយច្បាប់សិទ្ធិមនុស្ស និងត្រូវបានអនុវត្តតាមលក្ខណៈសមរម្យបំផុត រួមទាំងការពិចារណា ទៅលើជម្រើសផ្សេងទៀត អនុលោមទៅតាមនីតិវិធីត្រឹមត្រូវ និងគោរពសិទ្ធិទទួលបានព័ត៌មានពេញលេញ ការពិគ្រោះយោបល់ត្រឹមត្រូវ យល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុនដល់ប្រជាពលរដ្ឋដែលរងគ្រោះ។ រដ្ឋក៏ត្រូវចាត់វិធានការចាំបាច់នានាដើម្បីកាត់បន្ថយផលប៉ះពាល់ពីការបណ្តេញចេញ ដើម្បីធានាថានឹងពុំមានលទ្ធផលដែលបណ្តាលឱ្យពលរដ្ឋគ្មានផ្ទះសម្បែងនោះឡើយ[5] និងធានាថាប្រជាពលរដ្ឋដែលត្រូវបានបណ្តេញចេញត្រូវបានផ្តល់នូវសំណងសមរម្យជាមុន និងដំណោះស្រាយសមស្រប។[6]

រដ្ឋត្រូវបានតម្រូវឱ្យមានការការពារប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ដែលអនុវត្តដោយភាគីទីបីរួមទាំងធុរកិច្ចផងដែរ។

**ធុរកិច្ចគឺស្ថិតនៅក្រោមកាតព្វកិច្ចគោរពសិទ្ធិមនុស្ស** រួមទាំងពុំត្រូវមានការបណ្តេញបុគ្គលចេញដោយបង្ខំ។[7]

ការការពារប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ គឺមិនសំដៅតែទៅលើសុវត្ថិភាពកាន់កាប់ដីធ្លីរបស់បុគ្គលម្នាក់នោះទេ ប៉ុន្តែត្រូវធានាចំពោះបុគ្គលទាំងអស់ រួមទាំងអ្នកទាំងឡាយដែលរស់នៅលើទីតាំងមិនទាន់ផ្លូវការ ទីជនបទ និងអ្នក

---

[3] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស 'សាលាកប័ត្រស្តីពីការបណ្តេញចេញដោយបង្ខំ លេខ ២៥/ការពិនិត្យមើលឡើងវិញទី១' (ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ឆ្នាំ២០១៥) ទំព័រ៥

[4] ក.អ.ស.ស.ស.វ 'យោបល់ទូទៅលេខ៧ ស្តីពីសិទ្ធិមានលំនៅឋានសមរម្យ៖ កាបណ្តេញចេញដោយបង្ខំ' (ក.អ.ស.ស.ស.វ ១៩៩៧) អ.ស.ប ឯកសារ អ៊ី/១៩៩៨/២២ កថាខ័ណ្ឌ១១

[5] ប្រភពដូចខាងលើ កថាខ័ណ្ឌ១៦

[6] ឧទាហរណ៍ដំណោះស្រាយសមរម្យ, សូមមើលរបាយការណ៍របស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, ដីធ្លី និងខ្នាតគំរូសិទ្ធិមនុស្ស និងការអនុវត្ត (ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ២០១៥) ទំព័រ២៩

[7] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, ដីធ្លី និងខ្នាតគំរូសិទ្ធិមនុស្ស និងការអនុវត្ត (លេខ២៦) ទំព័រ៨១

ជួលផងដែរ។[8]

**ការណែនាំអន្តរជាតិ ៖ ការហាមប្រាមការបណ្តេញចេញអំឡុងពេលកូវីដ១៩** 

ការបណ្តេញចេញដោយបង្ខំ គឺជាបញ្ហាដែលកាន់តែប្រឈមខ្លាំងនៅក្នុងបរិបទនៃជំងឺរាតត្បាតសកលដែលមិនធ្លាប់មានពីមុនមក ខណៈដែលបុគ្គលម្នាក់ៗត្រូវការលំនៅឋាន និងសន្តិសុខដ៏ប្រសើរបំផុត ដើម្បីការពារខ្លួនពីជំងឺកូវីដ១៩ និងគោរពតាមវិធានការការពាររបស់រដ្ឋាភិបាលដូចជាការធ្វើចត្តាឡីស័ក ការបិទខ្ទប់ ឬបម្រាមគោចរដែលតម្រូវឱ្យបុគ្គលស្នាក់នៅក្នុងផ្ទះ។

ជាការគួរឱ្យសោកស្តាយ ការរំលោភសិទ្ធិដីធ្លី និងការបណ្តេញចេញដោយបង្ខំ បានកើនឡើងនៅជុំវិញពិភពលោកទោះបីជាមានជំងឺរាតត្បាតសកលក៏ដោយ។ ប្រការនេះ បាននាំឱ្យអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិទទួលបានលំនៅឋានសមរម្យ បានជំរុញរដ្ឋទាំងអស់ចាត់វិធានការឱ្យបានគ្រប់គ្រាន់ ដើម្បីធានាការការពារប្រឆាំងនឹងការបណ្តេញចេញក្នុងអំឡុងពេល កូវីដ១៩ ដោយបានសង្កត់ធ្ងន់ថា លំនៅឋានគឺជាអ្នកការពារជួរមុខប្រឆាំងនឹងជំងឺឆ្លងកូវីដ១៩ និងបានថ្លែងថា ការបណ្តេញចេញក្នុងអំឡុងពេលជំងឺរាតត្បាតនេះ គឺប្រហាក់ប្រហែលនឹងការកាត់ទោសប្រហារជីវិត។[9] នៅក្នុងសេចក្តីណែនាំស្តីពីការហាមប្រាមការបណ្តេញចេញក្នុងអំឡុងពេលកូវីដ១៩ ចាប់ពីតាំងខែមេសា ឆ្នាំ ២០២០ អ្នករាយការណ៍ពិសេសក៏បានផ្តល់អនុសាសន៍ ដល់រដ្ឋទាំងឡាយរួមមាន៖

- បញ្ឈប់រាល់ការបណ្តេញចេញជាបន្ទាន់ចំពោះបុគ្គលគ្រប់រូបនៅគ្រប់ទីកន្លែង និងដោយសារហេតុផលណាមួយក៏ដោយ រហូតដល់ទីបញ្ចប់នៃជំងឺរាតត្បាតនេះ និងក្នុងរយៈពេលមួយសមរម្យបំផុត បន្ទាប់ពីព្រឹត្តិការណ៍នោះដោយមានករណីលើកលែងតិចតួចបំផុត
- បញ្ចប់ការបណ្តេញចេញដោយបង្ខំ ឬបន្លាស់ទីលំនៅនៃការតាំងទីលំនៅមិនទាន់ផ្លូវការ និងអនុវត្តតាមការណែនាំស្តីពីការការពារពលរដ្ឋនៅក្នុងការតាំងទីលំនៅមិនទាន់ផ្លូវការ[10]
- ធានាថាការបណ្តេញចេញណាមួយដែលត្រូវបានអនុម័តមុនពេលជំងឺរាតត្បាតត្រូវបានផ្អាក
- ផ្តល់ធនធានគ្រប់គ្រាន់ដើម្បីអនុវត្តការហាមប្រាមការបណ្តេញចេញប្រកបដោយប្រសិទ្ធភាព រួមទាំងធនធានដើម្បីតាមដាន និងទប់ស្កាត់តួអង្គឯកជនដែលអនុវត្តការបណ្តេញចេញក្រៅច្បាប់

---

[8] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស "ដីធ្លី និងខ្នាតគំរូសិទ្ធិមនុស្ស និងការអនុវត្ត (លេខ៦) ទំព័រ៧

[9] ("យូ.អិន.អេស.អ័រ.អ័រ.អេ.អេច") "កំណត់ហេតុនៃការណែនាំអំពីកូវីដ១៩ ៖ ការហាមប្រាមការបណ្តេញចេញ (ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ២៨ ខែមេសា ២០១៥) ទំព័រ៧

[10] ("យូ.អិន.អេស.អ័រ.អ័រ.អេ.អេច") "កំណត់ហេតុនៃការណែនាំអំពីកូវីដ១៩ ៖ ការពារប្រជាពលរដ្ឋដែលតាំងទីលំនៅមិនទាន់ផ្លូវការ" (ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១)

- ចាត់វិធានការដើម្បីធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងមិនត្រូវមានបុគ្គលណាម្នាក់ត្រូវបានបណ្ដេញដែលបណ្ដាលឱ្យក្លាយទៅជាអ្នកគ្មានផ្ទះសម្បែងក្នុងរយៈពេលដ៏សមរម្យ បន្ទាប់ពីការបញ្ចប់នៃជំងឺរាតត្បាត ដើម្បីដោះស្រាយឡើងវិញពីវិបត្តិសេដ្ឋកិច្ច និង
- ធានាឱ្យមានការទទួលបានយុត្តិធម៌សម្រាប់បុគ្គល គ្រួសារឬសហគមន៍ដែលបានទទួលរងការបណ្ដេញ ចេញ និងដែលកំពុងស្វែងរកមធ្យោបាយដោះស្រាយប្រកបដោយប្រសិទ្ធភាព។

## ២. ការបណ្តេញចេញដោយបង្ខំនៅកម្ពុជាក្នុងអំឡុងពេល កូវីដ១៩

ការរំលោភសិទ្ធិដីធ្លីស្ថិតក្នុងចំណោមបញ្ហាសិទ្ធិមនុស្ស ដែលកំពុងរីករាលដាលបំផុតនៅប្រទេសកម្ពុជាហើយការបណ្ដេញចេញដោយបង្ខំហាក់កើតឡើងជាធម្មតា។[11] ជាការគួរឱ្យព្រួយបារម្ភចំពោះការកើតមានឡើងនូវជំងឺរាតត្បាតកូវីដ ១៩ ចាប់តាំងពីដើមឆ្នាំ២០២០ មក ហើយក៏ពុំមានសញ្ញានៃការធូរស្បើយនៃការបណ្ដេញចេញដោយបង្ខំដែលបានបន្តកើតមានឡើងក្នុងអត្រាគួរឱ្យព្រួយបារម្ភនៅក្នុងព្រះរាជាណាចក្រផងដែរ។

គួរបញ្ជាក់ដែរថា នៅដើមដំបូងនៃការរីករាលដាលនៃជំងឺរាតត្បាតនេះ ប្រទេសកម្ពុជាបានជួបប្រទះនូវរលកចំនួនបីនៃការផ្ទុះឡើងនៃជំងឺកូវីដ ១៩ នៅក្នុងសហគមន៍ ចាប់តាំងពីខែវិច្ឆិកាឆ្នាំ ២០២០ មក។ រលកចុងក្រោយដែលបានចាប់ផ្ដើមនៅខែកុម្ភៈ ឆ្នាំ២០២១ នេះ ឃើញថាករណីកូវីដ១៩ បានកើនឡើងយ៉ាងគំហុក និងមានអ្នកស្លាប់ដោយសារកូវីដ១៩ដំបូងគេ ត្រូវបានរាយការណ៍នៅក្នុងប្រទេស។ ស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជាកាន់តែរីករាលខ្លាំង បណ្ដាលឱ្យរាជរដ្ឋាភិបាលដាក់ចេញនូវវិធានការរឹតត្បិតផ្សេងៗដើម្បីការពារការរីករាលដាលនៃជំងឺរាតត្បាត រួមមានការធ្វើចត្តាឡីស័ក ការបិទខ្ទប់ និងបម្រាមគោចរ។[12]

ដើម្បីអនុវត្តតាមវិធានការបែបនេះ និងការធានាថាសុវត្ថិភាពពលរដ្ឋ អាជ្ញាធរគួរធានាផ្ដល់នូវលំនៅឋានសមរម្យ ប៉ុន្តែអាជ្ញាធរបែរជាធ្វើការបណ្ដេញចេញដោយបង្ខំជារឿយៗទៅវិញដែលផ្ទុយពីគោលការណ៍ណែនាំជាតិ និងអន្តរជាតិ[13] ហើយនិងគោលការណ៍ណែនាំអន្តរជាតិដែលបានផ្ដល់អនុសាសន៍ឱ្យបញ្ឈប់រាល់ការបណ្ដេញចេញនៅអំឡុងពេលមានជំងឺរាតត្បាត (សូមមើលផ្នែកមុន) ដោយបង្ហាញពីភាពងាយរងគ្រោះបំផុតចំពោះអ្នកគ្មានផ្ទះសម្បែង និងការកើនឡើងនូវហានិភ័យនៃការចម្លងជំងឺកូវីដ១៩ក្នុងចំណោមសហគមន៍ងាយរងគ្រោះ។

---

[11] ម.ស.ម.ក សាលាកប័ត្រព័ត៌មាន ៖ ការបណ្ដេញចេញដោយបង្ខំនៅកម្ពុជា″ (ដែលមាននៅក្នុងឯកសារយោងទី២) និងសូមមើល កំណត់ត្រាសង្ខេបស្ដីពីធុរកិច្ច និងសិទ្ធិមនុស្ស គណនេយ្យភាពសាជីវកម្មចំពោះការរំលោភបំពានលើសិទ្ធិដីធ្លី (ម.ស.ម.ក ខែធ្នូ ឆ្នាំ២០២០)។

[12] ខ្មែរថាមស៍ កាលប្បវត្តិនៃជំងឺកូវីដ ១៩ នៅកម្ពុជានិងព្រឹត្តិការណ៍សហគមន៍ថ្ងៃទី២០ ខែកុម្ភៈ (ខ្មែរថាមស៍ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១) សម្រាប់ព័ត៌មានលម្អិតអំពីស្ថានភាពជំងឺកូវីដ ១៩ នៅកម្ពុជា សូមមើលរបាយការណ៍ស្ដីពីស្ថានភាពរួមរបស់អង្គការសុខភាពពិភពលោកនិងក្រសួងសុខាភិបាលកម្ពុជា ។

[13] សូមមើលសាលាកប័ត្រព័ត៌មានស្ដីពីការបណ្ដេញចេញដោយបង្ខំ (និង) សម្រាប់ព័ត៌មានលម្អិតស្ដីពីក្របខណ្ឌច្បាប់ក្នុងស្រុកដែលអនុវត្តសម្រាប់ប្រទេសកម្ពុជា

បន្ថែមពីលើនេះ ក្នុងខែមីនា ឆ្នាំ២០២១ រាជរដ្ឋាភិបាលក៏បានអនុម័តច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ និងជំងឺឆ្លងកាចសាហាវប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ("ច្បាប់កូវីដ១៩") ដែលមានភាពទូលាយ និងមិនច្បាស់លាស់ហើយធ្វើឱ្យមានការពិន័យលើសលុបផងដែរ។ ចាប់តាំងពីច្បាប់នោះអនុម័តមក អាជ្ញាធរបានប្រើប្រាស់ច្បាប់កូវីដ១៩នេះដើម្បីរារាំងសេរីភាពនៃការបញ្ចេញមតិ និងការប្រមូលផ្តុំរបស់ប្រជាពលរដ្ឋដោយធ្វើការចោទប្រកាន់ពួកគេថាបានរាំងស្ទះដល់ដំណើរការអនុវត្តវិធានការកូវីដ១៩ តាមមាត្រា១១ នៅពេលសម្តែងការយល់ឃើញទៅលើបញ្ហាពាក់ព័ន្ធនឹងជំងឺកូវីដ១៩ ឬការតវ៉ារកយុត្តិធម៌ដូចដែលបានគូសបញ្ជាក់នៅក្នុងករណីសិក្សាមួយចំនួននៅខាងក្រោម។

## ករណីសិក្សា ៖ ការបណ្តេញចេញដោយបង្ខំកើតឡើងឥតឈប់ឈរនៅប្រទេសកម្ពុជាចំពេលស្ថានការណ៍ជំងឺកូវីដ១៩កាន់តែអាក្រក់នៅក្នុងឆ្នាំ២០២១

ការបណ្តេញចេញដោយបង្ខំចុងក្រោយថ្មីៗដែលបានកត់ត្រាដោយ ម.ស.ម.ក ដោយរាប់ទាំងការប្រើប្រាស់កម្លាំងការឃាយឃី និងការគំរាមកំហែងដោយអាជ្ញាធររដ្ឋទៅលើអ្នករងការបណ្តេញចេញ និងការបំផ្លិចបំផ្លាញផ្ទះសម្បែង ដីដាំដំណាំដោយគ្មានការជូនដំណឹងជាមុន ដោយអាជ្ញាធរឬក្រុមហ៊ុនឯកជន រួមទាំងការឃាយឃីតាមផ្លូវតុលាការទៅលើអ្នកដែលត្រូវបានបណ្តេញចេញចំពោះការតវ៉ានឹងការបណ្តេញចេញនិងការទាមទារសំណងសមរម្យ។ អ្នករងគ្រោះពិតប្រាកដគឺប្រជាកសិករ និងជនភាគតិចរួមមានជនជាតិដើមភាគតិច ជនជាតិភាគតិចវៀតណាម និងសហគមន៍ជនជាតិចាមផងដែរ។

ឧទាហរណ៍ជាក់ស្តែងបំផុតដែលកត់ត្រាដោយ ម.ស.ម.ក នៅរយៈពេលប៉ុន្មានខែចុងក្រោយនេះរួមមាន ៖[14]

- **ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១ រាជធានីភ្នំពេញ៖** អាជ្ញាធរខណ្ឌច្បារអំពៅបានបោះបង្គោលព្រំដែនដើម្បីសង់របងព័ទ្ធជុំវិញដី៣០ហិកតាដោយធ្វើការហាមឃាត់ប្រជាពលរដ្ឋ១៥៨គ្រួសារ មិនឱ្យដាំដំណាំលើដីដែលពួកគេកាន់កាប់តាំងពីឆ្នាំ២០០៨មកម្លេះ។ ប្រជាពលរដ្ឋនិយាយថាពួកគេត្រូវបានរារាំងមិនឱ្យដាំដំណាំតទៅទៀតទេ ហើយកងកម្លាំងសន្តិសុខត្រូវបានដាក់ពង្រាយ។ អាជ្ញាធរបានអះអាងថាប្រជាពលរដ្ឋកំពុងកាន់កាប់ដីខុសច្បាប់ ហើយកន្លងមកតែងតែបដិសេធទទួលយកសំណង។[15]

- **ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ ខេត្តមណ្ឌលគិរី ៖** សមាជិកសហគមន៍ជនជាតិដើមភាគតិចពូនងបានរារាំងអិចស្កាវ៉ាទ័រមួយគ្រឿងរបស់អ្នកមានអំណាចនិងទ្រព្យសម្បត្តិម្នាក់ពីការឈូសឆាយដីព្រៃសហគមន៍នៅភូមិដាក់ដាំ ឃុំពូត្រែង នាំឱ្យក្រុមគ្រួសារជនជាតិពូនង២០០គ្រួសារស្វែងរកជំនួយពីអាជ្ញាធរមូលដ្ឋានដើម្បីឱ្យជួយការពារដីធ្លីសហគមន៍។ ដី

[14] បញ្ជីករណីទាំងឡាយនៅក្នុងសាលាកប័ត្រនេះមិនមែនជាបញ្ជីពេញលេញនៃករណីដែលបានកត់ត្រាដោយ ម.ស.ម.ក ក្នុងឆ្នាំ២០២១ នោះទេ

[15] ណាត សុភាព ពលរដ្ឋច្បារអំពៅតវ៉ាករណីអាជ្ញាធរបោះបង្គោលព័ទ្ធដី (វីអូឌីខ្មែរ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២១)

ឆ្លៀលចេញពីព្រៃសហគមន៍ភូមិត្រែងដែលជាដែនជម្រកសត្វព្រៃមានទំហំ២០០០ហិកតា និងជាលំនៅរបស់សហគមន៍ជនជាតិដើមភាគតិចពូនង។ ការឈូសកកាយដីទាំងនេះបានធ្វើឱ្យប៉ះពាល់ដល់អត្តសញ្ញាណ និងវប្បធម៌ប្រពៃណីរបស់ពួកគេ។[16]

- **ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ខេត្តកណ្តាល៖** ប្រជាពលរដ្ឋប្រមាណជា២០០គ្រួសារដែលរងផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះអន្តរជាតិភ្នំពេញថ្មីក្នុងខេត្តកណ្តាលបានបិទផ្លូវឆ្ពោះទៅទីតាំងគម្រោងនោះបន្ទាប់ពីម្ចាស់គម្រោងក្រុមហ៊ុនវិនិយោគទុនអណិកជនកម្ពុជានៅក្រៅប្រទេស ("អូស៊ីអាយស៊ី") បានប្រើត្រាក់ទ័រ និងចាប់ផ្តើមបំផ្លាញដំណាំស្រូវរបស់ពួកគេ។[17] ការតវ៉ានេះកើតចេញពីទំនាស់ដីធ្លីដែលមានជាយូរមក ហើយដែលនៅតែមិនអាចដោះស្រាយបានព្រោះកសិករទទួលបានសំណងតិចតួចពេកចំពោះការបាត់បង់ដីធ្លី ដែលធ្វើឱ្យពួកគេគ្មានផ្ទះសម្បែងរស់នៅ និងជួបភាពក្រីក្រ។ ការតវ៉ាបានបន្តអស់ពេលជាច្រើនខែទៀតដើម្បីទាមទារតម្លៃសំណងសមរម្យ។ ជាការឆ្លើយតប អាជ្ញាធរបានបំផ្លិចបំផ្លាញផ្លូវចូលទៅស្រែ និងផ្ទះរបស់ប្រជាពលរដ្ឋ។[18] ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ មានកម្លាំងប៉ូលីសនិងទាហានរាប់រយនាក់ដាក់ពង្រាយនៅលើដីមានទំនាស់ដើម្បីចាប់ផ្តើមកាប់ឈូសឆាយដី។[19] ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១ អ្នកភូមិប្រមាណជា៣០នាក់ត្រូវបានចាប់ខ្លួននៅពេលអ្នកទាំងនោះធ្វើការតវ៉ាមួយដែលមានអ្នកភូមិរងគ្រោះ១០០នាក់ចូលរួម។ ប៉ូលីសបានចោទអ្នកតវ៉ាថាប្រើអំពើហិង្សាមកលើខ្លួនជាហេតុបណ្តាលឱ្យប៉ូលីស១៣នាក់រងរបួស ខណៈដែលអ្នកតវ៉ា និងក្រុមគ្រួសារបានរាយការណ៍ថាគឺប៉ូលីសទៅវិញទេជាអ្នកប្រើអំពើហិង្សាមកលើពួកគេ ហើយថាអាជ្ញាធរបានបង្ខំឱ្យទទួលយកសំណងមិនសមរម្យ។ អាជ្ញាធរចាប់ផ្តើមរុះរើផ្ទះនៅលើដីមានជម្លោះកាត់ផ្តាច់ចរន្តអគ្គិសនី និងដកយកត្រាក់ទ័រនិងម៉ូតូពីប្រជាពលរដ្ឋ។ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ មានការចាប់ខ្លួនអ្នកតវ៉ា៩នាក់ពីក្នុងចំណោមអ្នកតវ៉ាទាំង៣០នាក់ ដែលក្នុងនោះមាន៤នាក់ជាស្ត្រី ពួកគេរងការចោទពីបទប្រព្រឹត្តហិង្សាដោយចេតនា ហើយប្រព្រឹត្តអំពើហិង្សាលើមន្ត្រីរាជការសាធារណៈមានស្ថានទម្ងន់ទោស រួមទាំងការញុះញង់ឱ្យ

---

16 ជាតិ ចំណាន ជនជាតិដើមភាគតិចខេត្តមណ្ឌលគិរីចោទប្រកាន់អ្នកមានអំណាចម្នាក់ថារំលោភយកដីសហគមន៍៥៣ហិកតារ (អាស៊ីសេរីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១)

17 សូមមើលឧទាហរណ៍ សន សារ៉ាត "គម្រោងព្រលានយន្តហោះមេហ្គាបន្សល់ទុកគ្រួសាររងគ្រោះរាប់រយគ្រួសារដែលកំពុងជួបការលំបាកក្នុងការរស់នៅ" (ខេមបូចាញ់ ថ្ងៃទី៥ ខែមិនា ឆ្នាំ២០២១)។ ឃួត; សុខាចារិយា "អ្នកភូមិតវ៉ារឿងការឈូសឆាយដីស្រែចំការសម្រាប់គម្រោងព្រលានយន្តហោះភ្នំពេញ" (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១)។

18 យុន សុគន្ធ "ប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះធ្វើការតវ៉ាជាថ្មី" (វីអូឌី ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១) យុត សុគន្ធ "អ្នកតវ៉ាករណីព្រលានយន្តហោះសន្យាបិទផ្លូវនៅសប្តាហ៍ក្រោយខណៈដែលអភិបាលខេត្តបដិសេធការបន្តទៅមុខ" (វីអូឌី ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១) ស៊ិន សារ៉ាត "ជម្លោះដីធ្លីគម្រោងព្រលានយន្តហោះខ្នាតធំបង្កឱ្យមានការតវ៉ា ការប៉ះទង្គិចនៅផ្លូវចូល" (ខេមបូចាញ់ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១១) ម៉ុច ដារ៉ា និង អាណាត បាលិហ្កា "អ្នកភូមិតវ៉ាការបំផ្លាញផ្លូវនៅគម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះថ្មី" (វីអូឌី ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១)

19 ស៊ិន សារ៉ាត "ទោះបីជាខ្វះដំណោះស្រាយក្តី អាជ្ញាធរបិទផ្លូវឱ្យក្រុមហ៊ុនអូស៊ីអាយស៊ីចាប់ផ្តើមឈូសឆាយដីដាំដំណាំរបស់ប្រជាពលរដ្ឋសម្រាប់គម្រោងព្រលានយន្តហោះខ្នាតធំ" (ខេមបូចាញ់, ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២១); អាស៊ីសេរី "ប៉ូលីសខ្មែរបានរារាំងអ្នកភូមិពីដីដែលរឹបអូសយកសម្រាប់គម្រោងព្រលានយន្តហោះ" (អាស៊ីសេរី ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២១)

ប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ពួកគេត្រូវបានបញ្ជូនទៅឃុំខ្លួនជាបណ្ដោះអាសន្ន។[20] អ្នកទាំងនោះត្រូវបានដោះលែងឱ្យនៅក្រៅឃុំនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ និងដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបន្ទាប់ពីបានធ្វើលិខិតសុំទោសទៅ អាជ្ញាធរដោយសន្យាថាឈប់តវ៉ាទៀត និងត្រូវបានបង្ខំឱ្យទទួលយកសំណងមិនសមរម្យពីក្រុមហ៊ុន។[21]

- **ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ រាជធានីភ្នំពេញ៖** រដ្ឋបាលសាលារាជធានីភ្នំពេញបានចេញបញ្ជាឱ្យពលរដ្ឋមានផ្ទះនៅលើទឹកតាមដងទន្លេសាបដែលភាគច្រើនជាជនជាតិវៀតណាម និងបងប្អូនជនជាតិភាគតិចចាមរុះរើផ្ទះសម្បែង និងផ្លាស់ប្ដូរទីលំនៅក្នុងរយៈពេល១សប្ដាហ៍បើពុំដូច្នោះទេនឹងប្រឈមចំណាត់ការតាមផ្លូវច្បាប់ ក្រោយមូលហេតុស្ដារសោភ័ណភាពទីក្រុង និងការព្រួយបារម្ភពីបញ្ហាបរិស្ថាន។[22] ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ អាជ្ញាធរក្រុងភ្នំពេញចាប់ផ្ដើមកម្ទេចផ្ទះសម្បែងផ្ទះបណ្ដែតទឹកដោយមិនបានផ្ដល់នូវទីតាំងថ្មី ឬក៏ដំណោះស្រាយជាសំណងដល់ម្ចាស់ផ្ទះទាំងនោះឡើយ។ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ អាជ្ញាធរបានដំណើរការនូវការបណ្ដេញចេញទ្រង់ទ្រាយធំទៅលើប្រជាពលរដ្ឋជាង ១០០០គ្រួសារពីទន្លេសាប។ ទោះបីជាមានការកើនឡើងជំងឺកូវីដ១៩ក្ដី សាលារាជធានីភ្នំពេញបានប្រកាសថានឹងមានការបណ្ដេញចេញថែមទៀត។[23] អ្នកខ្លះបានជួលផ្ទះរស់នៅបណ្ដោះអាសន្ន ខ្លះទៀតបានតាំងទីលំនៅជាបណ្ដោះអាសន្ននៅមាត់ទន្លេ ឬនៅតាមព្រំដែនកម្ពុជា-វៀតណាម ក្រោយពេលមានការរារាំងការចូលទៅក្នុងប្រទេសវៀតណាម។[24] រហូតមកដល់ពេលនេះ គ្មានគ្រួសារដែលរងការបណ្ដេញចេញណាមួយបានទទួលសំណងជាលំនៅសមរម្យនៅឡើយទេ។

- **ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ ខេត្តកណ្ដាល៖** កងកម្លាំងទាហានបានបង្ក្រាបទៅលើអ្នកតវ៉ានៅលើដីមួយកន្លែងនៅឃុំទួល ស្រុកអង្គស្នួល ខេត្តកណ្ដាល ដែលបានកាន់កាប់ដោយអ្នកភូមិប្រហែល ៣០០នាក់ ដោយបានវាយ និងបង្ករបួសធ្ងន់ដល់កសិករចំណាស់ម្នាក់មានវ័យ៥៦ឆ្នាំ។ ក្រុមអ្នកតវ៉ាបានព្យាយាមបញ្ឈប់រថយន្តឈូសឆាយវាលស្រែពួកគេជាមួយនឹងការដាក់របាំងរាំងដែលរដ្ឋាភិបាលគ្រោងប្រើសម្រាប់ទាហាននិងជាកន្លែងចាក់សម្រាមដោយគ្មានការផ្ដល់

[20] ម៉ិច ដារ៉ា "អ្នកតវ៉ារឿងព្រលានយន្តហោះ២១នាក់ត្រូវបានចាប់ខ្លួន ៩នាក់រងការចោទពីបទប្រើអំពើហិង្សា" (វីអូឌី ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១) និង "អ្នកតវ៉ារឿងព្រលានយន្តហោះត្រូវបានចោទប្រកាន់ពីបទប្រើអំពើហិង្សា រារាំង និងញុះញង់" (វីអូអេ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១)

[21] យុត សុគន្ធ "ក្រុមអ្នកតវ៉ាករណីព្រលានយន្តហោះ៩នាក់ត្រូវបានដោះលែងចំពេលមានការដាក់សម្ពាធឱ្យបញ្ចប់ការតវ៉ា" (វីអូអេ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១)

[22] ស៊ន សារ៉ាត "ផ្ទះបណ្ដែតទឹកទទួលបានការជូនដំណឹងរយៈពេល១សប្ដាហ៍ឱ្យចាកចេញពីលំនៅឋានមាត់ទន្លេនៅរាជធានីភ្នំពេញ" (ខេមបូចាញ្ញូយ៍ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២១) កាន់ វិច្ឆិកា និង ទុំ ម៉ាលីស "សហគមន៍ចិញ្ចឹមត្រីផ្ទះបណ្ដែតទឹកក្នុងរាជធានីភ្នំពេញប្រឈមនឹងការបណ្ដេញចេញ" (វីអូអេ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១)

[23] ភួង វ៉ាន់ថា "សាលារាជធានីភ្នំពេញស្នើឱ្យមានការបណ្ដេញចេញដោយបង្ខំសហគមន៍ជនជាតិចាមបន្ថែមទៀត" (ខេមបូឌានេស ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១)

[24] យី សុវុទ្ធី "អាជ្ញាធរវៀតណាមបិទទន្លេមេគង្គដើម្បីរាំងជនជាតិភាគតិចវៀតណាមរាប់រយនាក់ដែលបណ្ដេញពីផ្ទះបណ្ដែតទឹកនៅរាជធានីភ្នំពេញចូលទៅកាន់ប្រទេសវៀតណាម" (ខេមបូចាញ្ញូយ៍ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១) ដានីញែល គីតុន អុលសេន និង សំអឿន និស្ស័យបុណ្យ "សហគមន៍បណ្ដែតទឹក ជនជាតិវៀតណាមជាច្រើនត្រូវបានយកចេញពីការបណ្ដេញចេញក្នុងរាជធានីភ្នំពេញ" (វីអូឌី ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១) និង "អ្នកនេសាទដែលគ្មានប្រទេសត្រូវកម្ពុជាបណ្ដេញចេញ ដេញមកវិញដោយវៀតណាម" (វីអូឌី ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២១)

សំណងដល់ប្រជាពលរដ្ឋរងផលប៉ះពាល់នោះឡើយ។[25] កម្លាំងទាហានបានបញ្ជាក់ថាទាហានបានបាញ់ប្រជាពលរដ្ឋដើម្បីការពារខ្លួន ហើយដីមានទំនាស់នោះជាដីរបស់រដ្ឋ។[26] ប្រជាពលរដ្ឋបានអះអាងថាពួកគេបានអំពាវនាវឱ្យអាជ្ញាធរថ្នាក់ជាតិជួយរកដំណោះស្រាយសមរម្យមួយឱ្យពួកគេជុំវិញបញ្ហាដីមានទំនាស់ តែមិនទទួលបានជោគជ័យទេ។ នៅខែកញ្ញា ឆ្នាំ២០២១ កសិករដែលរងរបួសបានជូរស្បើយខ្លះហើយនោះ បានស្នើសុំម្តងទៀតទៅអាជ្ញាធរពាក់ព័ន្ធធ្វើការស៊ើបអង្កេតជាបន្ទាន់ហើយនាំខ្លួនជនល្មើសទៅតុលាការ។[27] អជ្ញាធរបានគំរាមគ្រួសារដែលរងផលប៉ះពាល់ផងដែរថាពួកគាត់នឹងមិនទទួលបានដំណងអ្វីឡើយ ប្រសិនបើពួកគាត់បដិសេធការផ្តល់សំណងដោយអាជ្ញាធរ និងបង្ខំពួកគាត់ឱ្យទទួលយកសំណងមិនសមរម្យ។[28]

- **ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ រាជធានីភ្នំពេញ៖** ប៉ូលីសប្រហែលជា៥០ទៅ៦០នាក់ និងកម្លាំងសន្តិសុខឯកជនរបស់ក្រុមហ៊ុន អូស៊ីអាយស៊ី បានយកអិចស្កាវ៉ាទ័រចំនួន២ឈូសឆាយដី២ហិកតានៅក្បែរទីក្រុងរណបដែលពួកគេកំពុងសាងសង់ក្នុងឃុំព្រែកលៀប ខណ្ឌជ្រោយចង្វារ ដោយគ្មានការជូនដំណឹងជាមុនទៅដល់ម្ចាស់ដីឡើយ។[29] ជម្លោះដីធ្លីជាមួយក្រុមហ៊ុន អូស៊ីអាយស៊ី និងប្រជាពលរដ្ឋខណ្ឌជ្រោយចង្វារបានអូសបន្លាយអស់រយៈពេល៩ឆ្នាំមកហើយក្នុងនោះមាន២៦គ្រួសាររងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុនមួយនេះ។ ប្រជាពលរដ្ឋបានប៉ុនប៉ងដួលដី ឬសាងសង់ផ្ទះថ្មីនៅលើដីដែលគេវាយកម្ទេចចោលប៉ុន្តែអាជ្ញាធរហាមឃាត់ពួកគេមិនឱ្យសាងសង់។ ជំនួសឱ្យការហាមឃាត់នោះ អាជ្ញាធរបានព្យាយាមបង្ខំឱ្យពលរដ្ឋទទួលយកសំណង១០ភាគរយនៃតម្លៃដីនៅទីនោះជាថ្នូរនឹងការអនុញ្ញាតឱ្យសង់ផ្ទះថ្មី។ ទោះជាយ៉ាងណាក៏ដោយពលរដ្ឋបានបន្តបដិសេធការផ្តល់សំណងដែលអាជ្ញាធរបង្ខំឱ្យទទួលយកនេះដោយចាត់ទុកថាសំណងនេះតិចពេក។ នៅខែសីហា ឆ្នាំ២០២១ គ្រួសារដែលរងផលប៉ះពាល់បានស្នើសុំទៅសាលារាជធានីភ្នំពេញឱ្យជួយរកដំណោះស្រាយចំពោះបញ្ហាដីនេះ និងស្នើសុំប័ណ្ណកម្មសិទ្ធិ។[30]
- **ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ ខេត្តមណ្ឌលគិរី៖** លំនៅឋានប្រជាពលរដ្ឋជនជាតិដើមភាគតិចពូនងប្រហែលជា១០០០គ្រួសារក្នុងខេត្តមណ្ឌលគិរី ត្រូវបានបំផ្លិចបំផ្លាញ ខណៈមន្ត្រីបរិស្ថានបានចោទប្រជាពលរដ្ឋទាំងនោះថាកំពុងរស់នៅលើដីរដ្ឋ បើទោះបីជាពលរដ្ឋបានអះអាងថាបានរស់នៅទីនោះជាច្រើនជំនាន់មកហើយ។ ក្រុមជនជាតិដើម

[25] អាស៊ីសេរី "អ្នកភូមិខ្មែរត្រូវបានបាញ់ដោយកងកម្លាំងសន្តិសុខចំពោះរឿងដាំដំណាំនៅលើដីមានជម្លោះ" (អាស៊ីសេរី ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២១) ស៊ីន សារ៉ាត "ទាហានបាញ់បុរសម្នាក់នៅលើដីមានជម្លោះក្នុងខេត្តកណ្តាល" (ខេមបូចាញូយ៍ ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២១)

[26] ស៊ុន ណារិន "អភិបាលខេត្តកណ្តាលចេញការពារការបាញ់ទៅលើអ្នកតវ៉ាដោយនិយាយថាកសិករដែលរងរបួសគឺបង្កឡើងដោយអចេតនា" (វីអូអេ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២១)

[27] អាស៊ីសេរី "ជនរងគ្រោះពីការបាញ់ប្រហាររបស់ទាហានករណីជម្លោះដីធ្លីកំពុងតែបន្តសុំស្ថាប័នដែលពាក់ព័ន្ធពន្លឿនយុត្តិធម៌" (អាស៊ីសេរី ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១)

[28] សន សារ៉ាត "គ្រួសារជាច្រើននៅស្រុកអង្គស្នួលត្រូវបានបង្ខំឲ្យទទួលយកសំណងនៅក្នុងជម្លោះដីធ្លីជាមួយក្រសួងការពារជាតិ" (ខេមបូចាញូយ៍ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១)

[29] គៀត សុរិទ្ធធារី "អាជ្ញាធរជ្រោយចង្វារឈូសឆាយដីប្រជាពលរដ្ឋនៅជិតទីក្រុងរណបរបស់ក្រុមហ៊ុនអូស៊ីសេរី" (វីអូឌី ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១)

[30] ជាតិ ចំណាន "ពលរដ្ឋរងផលប៉ះពាល់ពីការអភិវឌ្ឍនៅតំបន់ជ្រោយចង្វារបន្តទាមទារដំណោះស្រាយដីធ្លី" (អាស៊ីសេរី ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១)

ភាគតិចពូនងនៅស្រុកពេជ្រាដា ឃុំប៊ូស្រា បានឱ្យដឹងថាអាជ្ញាធរបានចាប់ផ្ដើមយុទ្ធនាការ "បង្ក្រាបបទល្មើសព្រៃឈើ" ដែលឈានទៅដល់ការបណ្ដេញចេញប្រជាពលរដ្ឋជនជាតិដើមភាគតិចជាច្រើននៅក្នុងខេត្ត។[31]

- **ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១ ខេត្តកណ្ដាល៖** អ្នកតំណាងចំនួន៣នាក់នៃដីកំពុងមានទំនាស់ចំនួន១៥០គ្រួសារ និងម្ចាស់ដីឯកជនម្នាក់នៅឃុំប្រាសាទ ស្រុកស្អាង ត្រូវបានចាប់ខ្លួនបន្ទាប់ពីម្ចាស់ដីដាក់ពាក្យបណ្ដឹងចោទប្រកាន់ថាកាន់កាប់ដីឯកជន។ ប្រជាពលរដ្ឋបានរស់នៅនិងដាំដំណាំលើដីនោះតាំងពីឆ្នាំ១៩៨០ រហូតដល់ឆ្នាំ២០១៩ នៅពេលដីចាប់ផ្ដើមមានទំនាស់ ហើយអ្នកភូមិត្រូវបានគេប្រាប់ឱ្យបញ្ឈប់ការដាំដំណាំលើដីតទៅទៀត។ ជម្លោះបានចាប់ផ្ដើមជាថ្មីម្ដងទៀត ក្រោយពេលអ្នកភូមិបានវិលត្រឡប់ទៅកាន់កាប់ដីឡើងវិញក្រោយពេលរោងចក្រដែលគេធ្វើការបានបិទទ្វារដោយសារជំងឺកូវីដ១៩ កាលពីឆ្នាំ២០២០។ នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១ តុលាការខេត្តកណ្ដាលបានចោទប្រកាន់ពួកគេពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ដែលនាំទៅដល់ការប្រមូលផ្ដុំអ្នកភូមិប្រមាណជា៥០នាក់នៅមុខក្រសួងយុត្តិធម៌នៅថ្ងៃបន្ទាប់ដើម្បីស្នើសុំឱ្យតុលាការដោះលែង។[32] នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២១ អ្នកតំណាងដែលជាប់ឃុំម្នាក់ក្នុងចំណោម៣នាក់បានស្លាប់ដោយមានការរាយការណ៍ថា មកពីមានបញ្ហាសុខភាពដោយសារកង្វះថ្នាំព្យាបាលនៅក្នុងពន្ធនាគារ។[33]

- **ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២១ ខេត្តក្រចេះ៖** ប្រជាពលរដ្ឋក្នុងស្រុកចិត្របុរី ខេត្តក្រចេះ ចោទក្រុមហ៊ុនឯកជនមួយថាបានរំលោភយកដីពួកគេ ហើយបានបញ្ជូនពួកគេទៅតុលាការក្រោយពេលមានការតវ៉ា។ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២១ អ្នកភូមិរាប់រយនាក់នៅក្នុងភូមិសាង ឃុំចង្ក្រង ស្រុកចិត្របុរី បានតវ៉ា និងរារាំងក្រុមហ៊ុនដែលធ្វើការឈូសឆាយដី។ សមាជិកសហគមន៍បានប្រាប់ឱ្យដឹងថាដីមានទំនាស់នោះគឺជាមួយក្រុមហ៊ុនឈ្មោះ មីកាស្អាត ដែលបានចាប់ផ្ដើមនៅឆ្នាំ២០២០លើផ្ទៃដី៨០០០ហិកតាដែលជាកម្មសិទ្ធិរបស់ក្រុមគ្រួសារពលរដ្ឋខ្មែរជាង៦០០គ្រួសារ ហើយដែល៦០ភាគរយនៃដីរងផលប៉ះពាល់គឺជាកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចពូនង។ អ្នកភូមិម្នាក់បានរាយការណ៍ថាក្រុមហ៊ុនបានឱ្យសន្តិសុខធ្វើការបង្ក្រាបគំរាមកំហែងប្រជាពលរដ្ឋមិនឱ្យធ្វើការតវ៉ា និងគំរាមប្ដឹងពួកគេទៅតុលាការ។[34]

---

[31] សុន មិនា "សហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តមណ្ឌលគិរីត្រូវបានបង្ខំឱ្យចាកចេញពីដី" (ខ្មែរថាមស៍ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១)

[32] សំ សុពេជ្រ "មានការតវ៉ាបន្ទាប់ពីអ្នកភូមិ៣នាក់ត្រូវបានចោទប្រកាន់ពីបទចូលទៅកាន់កាប់ទ្រព្យសម្បត្តិឯកជន" (ខេមបូចាញ្ញូយ៍ ថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១)

[33] អាស៊ីសេរី "ជនជាប់ឃុំដោយសារបញ្ហាដីធ្លីម្នាក់បានស្លាប់នៅពន្ធនាគារខេត្តកណ្ដាល" (អាស៊ីសេរី ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២១)

[34] យុត សុគន្ធ "អ្នកភូមិក្នុងខេត្តក្រចេះចោទក្រុមហ៊ុនឯកជនមួយថាបានឈូសឆាយរំលោភយកដីធ្លីនិងប្ដឹងពួកគេទៅតុលាការ" (វីអូឌីខ្មែរ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២១)

> *"សត្វអាចរស់នៅដោយគ្មានផ្ទះសម្បែងបាន ប៉ុន្តែមនុស្សវិញមិនអាចទេ។ ជំងឺកូវីដ១៩កំពុងវាយប្រហារពួកយើងឥឡូវនេះ ប្រជាពលរដ្ឋរកប្រាក់ចំណូលបានតិចតួចធ្វើឱ្យយើងខ្វះអាហារ ហើយពេលនេះយើងគ្មានផ្ទះសម្បែងទៀត ពិតជាពិបាកណាស់" ។*
> *សំអុន អ្នកដែលត្រូវបណ្ដេញចេញពីភូមិបឹងឈូកអេ (ខេមបូឌានេស)*

- **ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ រាជធានីភ្នំពេញ៖** អាជ្ញាធរមូលដ្ឋានបានរុះរើផ្ទះចំនួន៤៨ខ្នង របស់ប្រជាពលរដ្ឋដែលរស់នៅតាមមាត់ទន្លេសាបក្នុងសង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយគ្មានការជូនដំណឹងជាមុន និងគ្មានសំណង។ គ្រួសារប្រហែលជា៥០ ប៉ះពាល់ពីការរុះរើនេះ ហើយគ្រួសារភាគច្រើនគឺជាអាជីវករប្រមូលទិញសម្ភារៈសំណល់នៅក្នុងតំបន់ដើម្បីចិញ្ចឹមជីវិត។[35]

- **ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២១ រាជធានីភ្នំពេញ៖** អាជ្ញាធរមូលដ្ឋានបានរុះរើផ្ទះគ្រួសារដែលនៅសេសសល់ទាំង២០គ្រួសារនៅសហគមន៍បឹងឈូកអេ ខណ្ឌឫស្សីកែវ ដើម្បីធ្វើផ្លូវមួយខ្សែបន្ទាប់ពីបានជូនដំណឹងដល់ប្រជាពលរដ្ឋត្រឹមតែមួយសប្តាហ៍ប៉ុណ្ណោះ ហើយមិនបានផ្តល់សំណងដល់អ្នកដែលបណ្តេញចេញឡើយ។ ប្រជាពលរដ្ឋបានរាយការណ៍មកថាប៉ូលីសបានរុះរើផ្ទះដោយប្រើញញួរ ពូថៅ រណារ និងម៉ូទ័រខួង ហើយមានគ្រួសារមួយត្រូវប៉ូលីសចាប់យកចេញពីក្នុងផ្ទះមុនពេលរុះរើនៅចំពោះមុខពួកគេ។[36]

- **ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១ រាជធានីភ្នំពេញ៖** អាជ្ញាធរខណ្ឌមានជ័យ រាជធានីភ្នំពេញ បានធ្វើលិខិតជូនដំណឹងនៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១ ទៅគ្រួសារដែលរស់នៅក្បែរបឹងទំពុនបញ្ជាឱ្យពួកគេរុះរើផ្ទះក្នុងរយៈពេលមួយសប្តាហ៍ដើម្បីយកទីនោះធ្វើជាអាងស្តុកទឹកបើមិនដូច្នេះទេពួកគេត្រូវប្រឈមមុខនឹងផ្លូវច្បាប់ និងការពិន័យរដ្ឋបាល។ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ អាជ្ញាធរខណ្ឌជាង១០០នាក់បានចូលមកមើលទីតាំងប៉ុនប៉ងរុះរើផ្ទះប្រជាពលរដ្ឋ១០គ្រួសារ ដោយអះអាងថាម្ចាស់ផ្ទះកំពុងរស់នៅលើដីរដ្ឋហើយការរុះរើនោះនឹងមិនទទួលបានសំណងទេ។[37] ក្រោយពេលមានការតវ៉ាពីអ្នកភូមិ អាជ្ញាធរបានបញ្ឈប់ការរុះរើបន្ទាប់ពីបានរុះរើផ្ទះចំនួនពីរខ្នងហើយ។ នៅខែកញ្ញា ឆ្នាំ២០២១ ប្រជាពលរដ្ឋរងផលប៉ះពាល់បានជួសជុលផ្ទះឡើងវិញដោយបាននិយាយថាពួកគេរស់នៅទីនោះរយៈពេលជាង២០ឆ្នាំមក ហើយៗក៏មិនដឹងថាត្រូវទៅនៅឯណាក្រៅពីទីនេះដែរ។[38]

- **ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ ខេត្តស្វាយរៀង៖** តំណាងសហគមន៍ពីររូបនៃឃុំឈើទាល ស្រុកស្វាយជ្រុំ ត្រូវបានចាប់ និងឃុំខ្លួននៅក្នុងពន្ធនាគារខេត្តស្វាយរៀងពីករណីតវ៉ាបដិសេធទទួលយកសំណងចំពោះដីមានទំនាស់។ តំណាង

[35] អាស៊ីអាស៊ី"ពលរដ្ឋជិត៥០គ្រួសារស្នើសុំដំណោះស្រាយក្រោយអាជ្ញាធររុះរើផ្ទះដោយគ្មានសំណង" (អាស៊ីអាស៊ី ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២១)

[36] ដើរ៉ាលដ៍ហ្វ្លីន "ប្រជាពលរដ្ឋដែលរងការបណ្ដេញចេញបានដាក់ស្លាករដ្ឋាភិបាលថា 'ផ្តាច់ការ' បន្ទាប់ពីផ្ទះត្រូវបានបំផ្លាញ" (ខេមបូឌានេស ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១)

[37] ពក ខឺយ និង អ៊ូច សូនី "ផ្ទះនៅបឹងទំពុនត្រូវបានរុះរើ អ្នកព័ត៌មានត្រូវបានរាំង" (វីអូឌី ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១)

[38] ពក ខឺយ និង អ៊ូច សូនី "អ្នកភូមិបឹងទំពុនបានសាងសង់ផ្ទះរបស់ពួកគេដែលត្រូវបានរុះរើឡើងវិញ" (វីអូឌី ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១)

សហគមន៍ទាំងពីរនាក់បានរងការចោទប្រកាន់ក្រោមច្បាប់កូវីដ១៩ថ្មីចំពោះការល្មើសវិធានការសុខាភិបាល និងត្រូវជាប់ពន្ធនាគារ៣ឆ្នាំបើសិនជារកឃើញថាមានទោស។ អ្នកទាំងពីរធ្លាប់ទទួលរងការផាកពិន័យចំនួន២លានរៀល បន្ទាប់ពីបានបង្ហោះវីដេអូថតនៅលើទីតាំងដីមានទំនាស់ដោយមិនមានពាក់ម៉ាស។ ជម្លោះនេះកើតចេញពីអ្នកភូមិដែលរង់ចាំការបណ្តេញចេញដោយបង្ខំដើម្បីយកដីស្តារប្រឡាយដែលគេស្គាល់ថាទន្លេវ៉ៃគោII ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងធនធានទឹក។ គម្រោងអភិវឌ្ឍន៍នេះបានចាប់ដំណើរការតាំងពីឆ្នាំ២០០៩ មក ហើយប៉ះពាល់ដល់ប្រជាពលរដ្ឋ១២០គ្រួសារនៅលើផ្ទៃដី៩៩ហិកតា។ តាំងពីនោះមក អ្នកភូមិត្រូវបានអាជ្ញាធរបង្ខំឱ្យផ្តិតមេដៃលើកិច្ចសន្យាទទួលយកសំណងដែលមានតម្លៃទាប។[39]

ជារួម ចន្លោះពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២១ ការប្រមូលផ្តុំចំនួន៤ដែលធ្វើឡើងដើម្បីបញ្ឈប់ក្រុមហ៊ុនឯកជនពីការរំលោភយកឬឈូសឆាយផ្ទះ ឬដីធ្លីពួកគេត្រូវបានរងការបង្ក្រាប ហើយការប្រមូលផ្តុំមួយក្នុងចំណោមនេះត្រូវទទួលរងអំពើហិង្សាពីភាគីទីបីផងដែរ។[40]

## ៣.សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការបណ្តេញចេញដោយបង្ខំគឺជាការដកហូតនូវសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ហើយកំពុងបន្តមានក្នុងកម្រិតមួយគួរឱ្យព្រួយបារម្ភនៅក្នុងប្រទេសកម្ពុជាទោះបីជាប្រទេសកម្ពុជាកំពុងប្រឈមនឹងជំងឺកូវីដ១៩ក្តី។ ជារឿងសំខាន់ដែលរដ្ឋាភិបាលត្រូវធានាដល់សិទ្ធិមានលំនៅឋានសមរម្យរបស់ប្រជាពលរដ្ឋ ខណៈដែលរដ្ឋាភិបាលបានប្រឹងប្រែងដោះស្រាយការឆ្លងរីករាលដាលជំងឺឆ្លងនេះ។ ម.ស.ម.ក សូមផ្តល់នូវអនុសាសន៍មួយចំនួនជូនរដ្ឋាភិបាលដូចតទៅ៖

១. បញ្ឈប់រាល់ការបណ្តេញចេញដោយបង្ខំអំឡុងពេលដែលមានការរីករាលដាលនៃជំងឺកូវីដ១៩ ហើយគួរគិតគូរ ពីពេលវេលាសមស្រប ឱ្យស្របជាមួយនឹងអនុសាសន៍របស់អង្គការសហប្រជាជាតិ និងការពារពលរដ្ឋពីការបណ្តេញចេញដោយបង្ខំ និងការប្រើប្រាស់កងកម្លាំងដោយក្រុមហ៊ុនសាជីវកម្ម ឬភាគីទីបី

២. អនុវត្តតាមអនុសាសន៍របស់អង្គការសហប្រជាជាតិនៅក្នុងកំណត់ហេតុណែនាំពីជំងឺកូវីដ១៩ ស្តីពីការហាមឃាត់ការបណ្តេញចេញ និងកំណត់ហេតុណែនាំជំងឺកូវីដ១៩ក្នុងការការពារ ពលរដ្ឋដែលតាំងទីលំនៅមិនប្រក្រតី

៣. ចាត់វិធានការជាបន្ទាន់ ដើម្បីធានាថា ពលរដ្ឋដែលទទួលរងការបណ្តេញចេញដោយបង្ខំអំឡុងពេលមានការរីក

---

[39] សូមមើល ជា សុខនី “កសិករនៅខេត្តស្វាយរៀងត្រូវបានបង្ខំឱ្យទទួលយកកិច្ចព្រមព្រៀងដីធ្លីបន្ទាប់ពីមានការចាប់ខ្លួនតំណាងសហគមន៍” (ខេមបូចាញ្ញូយ៍ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១), ម៉ិច ដារ៉ា សេង ថៃ និង យុត សុគន្ធ “អ្នកតវ៉ាដីធ្លីនៅខេត្តស្វាយរៀងត្រូវបានចាប់ខ្លួនក្រោមច្បាប់កូវីដ១៩” (វីអូឌី ថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០២១)

[40] គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ទិន្នន័យឃ្លាំមើល

រាលដាលនៃជំងឺកូវីដ១៩ទទួលបានសំណងសមរម្យពីការបាត់បង់ដីធ្លី ហើយជួយពួកគេឱ្យមានលំនៅឋានសមរម្យ ដើម្បីការពារខ្លួនពីជំងឺកូវីដ១៩

៤. បញ្ឈប់ការប្រើប្រាស់កម្លាំងបង្ខំ ការគំរាមកំហែង ការសម្លុត និងការឃាយឃីតាមផ្លូវតុលាការទៅលើប្រជាពលរដ្ឋដែលរងការបណ្ដេញចេញដោយបង្ខំដែលធ្វើការតវ៉ាដោយសន្តិវិធី ឬស្វែងរកវិធីធ្វើការតវ៉ាប្រឆាំងការបណ្ដេញចេញដោយបង្ខំ និងសំណងសមរម្យ និង

៥. ធានាឱ្យមានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពលើគ្រប់ករណីរំលោភបំពានសិទ្ធិមនុស្សដែលកើតចេញពីការបណ្ដេញចេញដោយបង្ខំ និងធានាថារាល់ដំណោះស្រាយគឺអនុវត្តស្របទៅតាមបទដ្ឋានអន្តរជាតិ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្សរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា តាមរយៈលេខទូរស័ព្ទ ((+៨៥៥) (០)១២ ៩៤១ ២០៦ ឬតាមរយៈអ៊ីមែល vann.sophath@cchrcambodia.org.